**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

Ministry of Labour and Vocational Training

គាំពារសង្គមកម្ពុជា

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១៧)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១២ ៤១០នាក់ នៃរោងចក្រ សហគ្រាស ទាំង៤៤ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៤៤ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០

បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍
ចំនួន ៤៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 30 |
| 1 | ក្រុមហ៊ុនឌី ឡាកស៍ អិនធើណេសិនណល ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុនប៊ីរី អឹភែរឹល (ខេមបូឌា) | ភ្នំពេញ |
| 4 | ក្រុមហ៊ុនឌីអេសអិល2 អេនធើប្រាយ | ភ្នំពេញ |
| 5 | ក្រុមហ៊ុនស៊ីន ឡាន (ខេមបូឌា)ហ្គាមេន ខមភេនី លីមីធីត | ភ្នំពេញ |
| 6 | ក្រុមហ៊ុនឌី&ជេ (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 7 | ក្រុមហ៊ុនសេីង យ៉ុង ហ្គាមែនហ្វាក់តូរី ខូអេលធីឌី | ភ្នំពេញ |
| 8 | ក្រុមហ៊ុនឡុង ឈឹង ស៊ូ ផាត ឯ.ក | កំពង់ចាម |
| 9 | ក្រុមហ៊ុនគ័ន ម៊ីង ហ៊ែនប៉ែក (ខេមបូឌា) អិនដាសស្ទ្រៀល ឯ.ក | កណ្តាល |
| 10 | ក្រុមហ៊ុនអេលីតវីន (ខេមបូឌា) ឯ.ក | កណ្តាល |
| 11 | ក្រុមហ៊ុនវេមហ្វា លេឌើរ ឯ.ក | កណ្តាល |
| 12 | ក្រុមហ៊ុនភីភីអិន ភីសយ អឹថយខូអិលធីឌី | កណ្តាល |
| 13 | ក្រុមហ៊ុនវីងយីង(ខេមបូឌា)ហ្គាមេនហ្វាក់ធើរី អិលធីឌី | កណ្តាល |
| 14 | ក្រុមហ៊ុនឃ្វៃ យ៉ាង ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 15 | ក្រុមហ៊ុនអេមិណិន ហ្គាម៉ិន(ខេមបូឌា) លីមីធីត | កណ្តាល |
| 16 | ក្រុមហ៊ុនញូអាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត | កណ្តាល |
| 17 | ក្រុមហ៊ុនខេមបូឌានស៊ីកនេតឈ័រ ថេកស្តាយ ឯ ក | ស្វាយរៀង |
| 18 | ក្រុមហ៊ុនឃីងម៉េកឃើ(ខេមបូឌា)ហ្វូតវែរ | ស្វាយរៀង |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 19 | ក្រុមហ៊ុនយើង អ៊ីធើណល (ខេមបូឌា) | ស្វាយរៀង |
| 20 | ក្រុមហ៊ុនវ៉ាយ ធី ស៊ី ខបប៉ូរេសិន | កំពង់ស្ពឺ |
| 21 | ក្រុមហ៊ុនម៉ូណូភា (ខេមបូឌា) ខូ អិល ធីឌី (1) | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុនម៉ូណូភា (ខេមបូឌា) ខូ អិល ធីឌី (2) | កំពង់ស្ពឺ |
| 23 | ក្រុមហ៊ុនមីង ហៃ្វ អេនធើប្រាយ(ខេមបូឌា)ឯ.ក. | កំពង់ស្ពឺ |
| 24 | ក្រុមហ៊ុនញូខាំមើ ឡាក់ហ្គេដ អេនប៊ែក (ខេមបូឌា) មេនូហ្វេកធីរីង ឯ.ក | កំពង់ស្ពឺ |
| 25 | ក្រុមហ៊ុនហុងកុងវីនហ្វៀរហ្គាមេន(ខេមបូឌា)អិលធីឌី | កំពង់ស្ពឺ |
| 26 | ក្រុមហ៊ុនជីង ហ៊្វយ សៃ ព្រីនធីង ឯ.ក | កំពង់ស្ពឺ |
| 27 | ក្រុមហ៊ុនហាធ់រអ៊ិនធើណេសិនណល(ខេមបូឌា)ឯ.ក | តាកែវ |
| 28 | ក្រុមហ៊ុនស៊ី ស៊ី អេហ្វ ស៊ូមេនូហ្វេកធើរី | តាកែវ |
| 29 | ក្រុមហ៊ុនដាប់ប៊ែលយូអ៊ីជីស៊ី ម៉ែនញ៉ូហ្វែកធីរីង លីមីតធីត | ព្រះសីហនុ |
| 30 | ក្រុមហ៊ុនខេមបូឌាន សាន់វ៉ាយ ហ្គាមេន ខូអិលធីឌី | ព្រះសីហនុ |
| **ខ. វិស័យទេសចរណ៍** | | **14** |
| 31 | ក្រុមហ៊ុនអលខ្មែរ (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 32 | ក្រុមហ៊ុនអូរៀរ ហូថេល (ខេមបូឌា) ឯ. ក | ភ្នំពេញ |
| 33 | ក្រុមហ៊ុនកាំបូឌីយ៉ាណា អ៊ិនវេស្តមេនធ៍ (ភ្នំពេញ) ភីធីអ៊ី អែលធីឌី | ភ្នំពេញ |
| 34 | ក្រុមហ៊ុនខមមិនអេរៀ (ខេមបូឌា) | សៀមរាប |
| 35 | ក្រុមហ៊ុនអេប៉ិច ខេមបូឌា ត្រាវ៉ែល ស៊ែរវីស | សៀមរាប |
| 36 | ក្រុមហ៊ុនវីត្រូ អ៊ិនវេសមេន | សៀមរាប |
| 37 | ក្រុមហ៊ុនអេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 38 | ក្រុមហ៊ុនរ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 39 | សណ្ឋាគារ ស្វាយលីង | សៀមរាប |
| 40 | សណ្ឋាគារគូលែន | សៀមរាប |
| 41 | ក្រុមហ៊ុនអឹបៅអេស៊ា | សៀមរាប |
| 42 | ក្រុមហ៊ុនដឺ ប៊ីច សៀមរាប ឯ.ក | សៀមរាប |
| 43 | ក្រុមហ៊ុនត្រេល អហ្វ ឥណ្ឌូឆាយណា | សៀមរាប |
| 44 | ក្រុមហ៊ុនយូនៀន ឈៃលែន ហ្គ្រោស ឯ.ក | ព្រះសីហនុ |